# ស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា

## ជំពូក ៣

## ការត្រួតពិនិត្យប្រតិបត្តិករសកម្មភាពមីន

---

អគ្គលេខាធិការដ្ឋាន
អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន
អគារថ្មីផ្លូវលេខ ២៧៣កែង៥១៦ សង្កាត់ទួលសង្កែ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទលេខ: ០២៣-៨៨៥-៩៤១|០២៣-៨៨១-៤៩២
ទូរសារ: +885-23-881-308
អ៊ីម៉ែល: deth@cmaa.gov.kh
គេហទំព័រ: www.cmaa.gov.kh

មាតិកា

## ឫ ៙ [illegible] ៦


សេចក្តីផ្តើម ..... iii
ការត្រួតពិនិត្យប្រតិបត្តិករសកម្មភាពមីន ..... 1
១. វិសាលភាព ..... 1
២. វាក្យសព្ទ និងនិយមន័យ ..... 1
៣. គោលការណ៍ទូទៅ ..... 2
៤. តម្រូវការទូទៅ ..... 2
៤.១ ការធ្វើផែនការ និងការរៀបចំ ..... 2
៤.២ ការត្រួតពិនិត្យ ..... 4
៤.៣ ការវិភាគលើមូលហេតុ ..... 7
៤.៤ ឆ្លើយតបនឹងមិនអនុលោមភាព ..... 8
៥. ក្រុមត្រួតពិនិត្យ - កាតព្វកិច្ចទូទៅ ..... 8
៥.១ ទូទៅ ..... 8
៥.២ ផ្នែកត្រួតពិនិត្យ ..... 8
៥.៤ ឯករាជ្យភាព អព្យាក្រិតភាព និងសុចរិតភាព ..... 9
៦. ការទទួលខុសត្រូវ ..... 10
៦.១ អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកម្ចាត់មីន និងសង្គ្រោះជនពិការដោយសារមីន ..... 10
៦.២ ប្រតិបត្តិករសកម្មភាពមីន ..... 10
៦.៣ ម្ចាស់ជំនួយ និងអ្នកពាក់ព័ន្ធផ្សេងទៀត ..... 11
ឧបសម្ព័ន្ធ ១៖ ភ្ជាប់មកជាមួយទម្រង់ត្រួតពិនិត្យ (១២) ..... 12
ឧបសម្ព័ន្ធ ២៖ បញ្ជីណែនាំលើការកម្រិតមិនអនុលោមភាព ..... 12
ឧបសម្ព័ន្ធ ៣៖ ការណែនាំស្តីពីការត្រួតពិនិត្យគុណភាពដីដែលបានកាត់បន្ថយ ..... 13

## សេចក្តីផ្តើម

ការគ្រប់គ្រងគុណភាពប្រតិបត្តិករសកម្មភាពមីន អនុវត្តតាមការត្រួតពិនិត្យដំណើរការសកម្មភាពមីនរបស់ពួកគេ។ ការចុះត្រួតពិនិត្យតាមទីវាល ជាមុខងារសំខាន់មួយនៃការគ្រប់គ្រងគុណភាព ក្នុងការត្រួតពិនិត្យតាមរយៈការប្រមូល និងវិភាគព័ត៌មានអំពីការអនុវត្តដំណើរការសកម្មភាពមីន និងផលិតផលក៏ដូចជាការអនុវត្តគោលការណ៍ត្រួតពិនិត្យ និងដំណើរការចំពោះសកម្មភាពទាំងអស់ដែលស្ថិតនៅក្រោមប្រធានបទសកម្មភាពមីន។

អាជ្ញាធរមីននឹងអនុវត្តការត្រួតពិនិត្យបន្ថែម ដើម្បីបញ្ជាក់ថាប្រតិបត្តិករសកម្មភាពមីនកំពុងអនុវត្តតាមបទដ្ឋានប្រតិបត្តិការ និងគោលការណ៍ណែនាំដែលបានអនុម័តដែលនាំឱ្យការបោសសម្អាតមីន និងសកម្មភាពមីនផ្សេងៗទៀតមានសុវត្ថិភាព ប្រសិទ្ធភាព និងប្រសិទ្ធផល។ អាជ្ញាធរមីនអនុវត្តសកម្មភាពត្រួតពិនិត្យតាមរយៈការអង្កេត ការកត់ត្រា ការវិភាគ និងការធ្វើរបាយការណ៍។

ស្តង់ដានេះផ្តល់ក្របខ័ណ្ឌការងារសម្រាប់អនុវត្តប្រព័ន្ធត្រួតពិនិត្យ ដែលជាផ្នែកមួយនៃដំណើរការសកម្មភាពមីននៅកម្ពុជា។ ស្តង់ដានេះកំណត់ពីតម្រូវការអប្បបរមាសម្រាប់ប្រព័ន្ធត្រួតពិនិត្យសកម្មភាពមីន។ ព័ត៌មានលម្អិតអំពីការចុះត្រួតពិនិត្យទីវាល និងការត្រួតពិនិត្យគុណភាពផ្ទៃដីបោសសម្អាតមីនហើយមាននៅក្នុងបណ្តាឧបសម្ព័ន្ធនានានៃស្តង់ដានេះ។

# ការត្រួតពិនិត្យប្រតិបត្តិករសកម្មភាពមីន

## ១. វិសាលភាព

ស្តង់ដានេះផ្តល់នូវគោលការណ៍ណែនាំ សម្រាប់ការអនុវត្តប្រព័ន្ធត្រួតពិនិត្យលើប្រតិបត្តិករសកម្មភាពមីននៅកម្ពុជា។ ប្រតិបត្តិករសកម្មភាពមីន អាចប្រើប្រាស់គោលការណ៍ណែនាំនេះជាមូលដ្ឋានសម្រាប់ការត្រួតពិនិត្យផ្ទៃក្នុង។

## ២. វាក្យសព្ទ និងនិយមន័យ

- **ការត្រួតពិនិត្យ**៖ (១) គឺជាប្រព័ន្ធប្រមូលទិន្នន័យដែលទាក់ទងនឹងសូចនាករ ដើម្បីផ្តល់ព័ត៌មានដល់ថ្នាក់ដឹកនាំអំពីវឌ្ឍនភាពការងារ សមិទ្ធផល និងការអនុលោមតាមបទដ្ឋាន។ (២) កំណត់វិធីសាស្ត្រត្រួតពិនិត្យ ការវាស់វែង ពេលវេលាត្រួតពិនិត្យ ការវិភាគ និងការវាយតម្លៃលទ្ធផល ទៅលើប្រព័ន្ធដំណើរការ ឬសកម្មភាពអ្វីមួយ។

- **អង្គភាពចំណុះ**៖ គឺជាផ្នែកមួយនៃប្រតិបត្តិករសកម្មភាពមីន ដែលមានប័ណ្ណទទួលស្គាល់ឱ្យអនុវត្តសកម្មភាពមីនមួយ ឬច្រើនដូចជា៖ ការស្រាវជ្រាវមិនបច្ចេកទេស (NTS) ការស្រាវជ្រាវបច្ចេកទេស (TS) ការបោសសម្អាត ការកម្ទេចគ្រាប់មិនទាន់ផ្ទុះ (EOD) ការអប់រំពីគ្រោះថ្នាក់ដោយសារយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ (EORE) ឬការចាត់អាទិភាពការងារបោសសម្អាតមីន។

- **ក្រុមត្រួតពិនិត្យ**៖ គឺជាក្រុមគ្រប់គ្រងគុណភាពរបស់អាជ្ញាធរមីន ដែលទទួលខុសត្រូវក្នុងការគ្រប់គ្រង និងអនុវត្តប្រព័ន្ធត្រួតពិនិត្យថ្នាក់ជាតិ។

- **ការគ្រប់គ្រងគុណភាព (QM)**៖ គឺជាសកម្មភាពគ្រប់គ្រងគុណភាពប្រតិបត្តិករសកម្មភាពមីន។ សកម្មភាពនេះរួមមាន៖ ការបង្កើតគោលការណ៍ គោលដៅ ការធ្វើផែនការ ការត្រួតពិនិត្យ ការធានា និងការកែលម្អគុណភាព។

- **ការធានាគុណភាព (QA)**៖ ជាផ្នែកមួយនៃការគ្រប់គ្រងគុណភាព ដោយផ្តោតលើការផ្តល់ទំនុកចិត្តថាតម្រូវការគុណភាពនឹងសម្រេចបាន។ ការធានាគុណភាព គឺជាដំណើរការកសាងទំនុកចិត្តដោយផ្អែកលើភស្តុតាង ដែលធានាថាតម្រូវការគុណភាពនឹងសម្រេចបាន។ ការធានាគុណភាព គឺជាសកម្មភាពដែលប្រតិបត្តិករសកម្មភាពមីន អនុវត្តក្នុងបំណងធានាថាតម្រូវការគុណភាពនឹងសម្រេចបាន។

- **ការត្រួតពិនិត្យគុណភាព (QC)**៖ គឺជាផ្នែកមួយនៃការគ្រប់គ្រងគុណភាព ដែលផ្តោតលើការសម្រេចបាននូវតម្រូវការគុណភាព។ ការត្រួតពិនិត្យគុណភាពត្រូវសួរថា "តើយើងទទួលបាននូវអ្វីដែលយើងចង់បាន ឬនៅ?"។

- **កំហុសភ្លាំងភ្លាត់** គឺជាសកម្មភាពអចេតនា ឬមិនបានគ្រោងទុក ឧទាហរណ៍៖ ច្រលំចុចប៊ូតុងលើឧបករណ៍ណាមួយដោយការភ្លាត់។ ជាធម្មតាវាជាកំហុសមួយដែលកើតឡើងដោយអចេតនា។

- **កំហុសភ្លេចភ្លាំង៖** គឺជាសកម្មភាពខុសឆ្គងនៅពេលនរណាម្នាក់មិនបានធ្វើអ្វីមួយដោយសារការមិនយកចិត្តទុកដាក់ ឬការមិនចងចាំ។
- **កំហុសអចេតនា** គឺកើតឡើងនៅពេលនរណាម្នាក់ធ្វើអ្វីមួយដោយជឿថាវាត្រឹមត្រូវ តែតាមពិតវាជាការខុសឆ្គង។ មូលហេតុនៃការខុសឆ្គងនេះបណ្តាលមកពីការហ្វឹកហ្វឺនមិនត្រឹមត្រូវ ឬការវាយតម្លៃស្ថានការណ៍ខុស។
- **ការបំពាន** (កំហុសដោយចេតនា) គឺជាកំហុសឆ្គងដែលខុសពីការភ្លាំងភ្លាត់ ភ្លេចភ្លាំង និងកំហុសអចេតនា ព្រោះវាជាសកម្មភាពដោយចេតនា ឬសកម្មភាពមិនត្រឹមត្រូវ។ ការបំពានកើតឡើងនៅពេលនរណាម្នាក់ធ្វើអ្វីមួយដោយចេតនា ទោះជាដឹងថាវាផ្ទុយនឹងច្បាប់ក៏ដោយ ឧទាហរណ៍៖ មិនបានអនុវត្តតាមនីតិវិធីឱ្យបានត្រឹមត្រូវព្រោះចង់កេងពេលវេលា និងកាត់បន្ថយការងារ។

## ៣. គោលការណ៍ទូទៅ

ការត្រួតពិនិត្យ គឺជាផ្នែកមួយដ៏សំខាន់ក្នុងការគ្រប់គ្រងគុណភាពដំណើរការសកម្មភាពមីន។ បន្ថែមពីការផ្តល់ប័ណ្ណទទួលស្គាល់ និងអាជ្ញាប័ណ្ណប្រតិបត្តិការ ការត្រួតពិនិត្យដំណើរការ និងផលិតផលនៃសកម្មភាពមីន បានផ្តល់ឱ្យអាជ្ញាធរមីននូវទំនុកចិត្តថា ប្រតិបត្តិករសកម្មភាពមីនបានអនុវត្តសកម្មភាពដោយអនុលោមទៅតាមកាតព្វកិច្ចរបស់ខ្លួន។

ដើម្បីសម្រេចបានគុណភាពការត្រួតពិនិត្យ ត្រូវពិនិត្យមើលសមត្ថភាពប្រតិបត្តិករសកម្មភាពមីន (បុគ្គលិក ឧបករណ៍ និងនីតិវិធី) និងសង្កេតមើលថាតើសមត្ថភាពទាំងនេះត្រូវបានគេអនុវត្តយ៉ាងដូចម្តេច។ ការត្រួតពិនិត្យបន្ថែម ជួយបំពេញឱ្យប្រព័ន្ធគ្រប់គ្រងគុណភាពផ្ទៃក្នុងរបស់ប្រតិបត្តិករសកម្មភាពមីនអនុវត្តបានត្រឹមត្រូវ ប៉ុន្តែមិនមែនជាការទទួលខុសត្រូវលើផ្នែកសុវត្ថិភាព ប្រសិទ្ធភាព និងប្រសិទ្ធផលជំនួសឱ្យប្រតិបត្តិករនោះឡើយ។

ការត្រួតពិនិត្យនឹងត្រូវបានអនុវត្តផងដែរ លើការអនុវត្តបង្ហាញក្នុងចំការមីនសប្បនិមិត្តមុនពេលចាប់ផ្តើមអនុវត្តគម្រោងបោសសម្អាត ដែលជាផ្នែកមួយនៃដំណើរការផ្តល់ប័ណ្ណទទួលស្គាល់ និងអាជ្ញាប័ណ្ណប្រតិបត្តិការ។

## ៤. តម្រូវការទូទៅ

### ៤.១ ការធ្វើផែនការ និងការរៀបចំ

ការចុះត្រួតពិនិត្យដល់ការដ្ឋានរបស់ក្រុមត្រួតពិនិត្យអាជ្ញាធរមីន គួររៀបចំឡើងជាមួយប្រតិបត្តិករដែលនឹងត្រូវត្រួតពិនិត្យ ដោយមានបញ្ជាក់ពីពេលវេលា និងទម្រង់នៃការត្រួតពិនិត្យ។ មុនពេលចុះត្រួតពិនិត្យ ក្រុមត្រួតពិនិត្យអាជ្ញាធរមីនគួរអានរាល់ឯកសារពាក់ព័ន្ធនានាដូចជា៖ កិច្ចព្រមព្រៀងបោសសម្អាតមីន ប័ណ្ណទទួលស្គាល់ និងអាជ្ញាប័ណ្ណប្រតិបត្តិការ នីតិវិធីអនុវត្តនានា របាយការណ៍ត្រួតពិនិត្យលើកមុន របាយការណ៍ត្រួតពិនិត្យគុណភាព របាយការណ៍ស៊ើបអង្កេត និងឯកសារផ្សេងៗទៀតដែលជួយឱ្យក្រុមត្រួតពិនិត្យអាចធ្វើកម្មវិធីចុះត្រួតពិនិត្យ។

ការចុះត្រួតពិនិត្យដល់ការដ្ឋានត្រូវបានធ្វើឡើងដើម្បីប្រមូលទិន្នន័យ/ភ័ស្តុតាង អំពីការអនុវត្ត របស់ប្រតិបត្តិករសកម្មភាពមីន ស្វែងរកចំណុចដែលត្រូវកែលំអ និងកសាងទំនុកចិត្តលើគុណភាពនៃ សកម្មភាព និងផលិតផលសកម្មភាពមីន។ មុនពេលចុះត្រួតពិនិត្យ ក្រុមត្រួតពិនិត្យអាជ្ញាធរមីនគួរជូន ដំណឹងដល់ប្រតិបត្តិករសកម្មភាពមីនអំពីគោលបំណង កម្មវិធី និងតម្រូវការរៀបចំ (ដូចជា ការធានាឱ្យ មានឯកសារជាក់លាក់ ឬបុគ្គលិកសំខាន់ៗ)។ កាលបរិច្ឆេទ និងពេលវេលាជាក់លាក់នៃការចុះត្រួត ពិនិត្យអាចជូនដំណឹងជាមុន ឬមិនចាំបាច់ជូនដំណឹង។

## ៤.១.១ ពេលវេលា និងកម្រិតនៃការត្រួតពិនិត្យ

ពេលវេលានៃការចុះត្រួតពិនិត្យដល់ការដ្ឋាន គួរកែសម្រួលទៅតាមលទ្ធផលនៃការចុះត្រួត ពិនិត្យមុនៗ បទពិសោធន៍របស់ប្រតិបត្តិករ និងលក្ខណៈនៃសកម្មភាព។

**ក្រុមត្រួតពិនិត្យគួរតែពិចារណាលើការអនុវត្តត្រួតពិនិត្យ“ រឹតបន្តឹង” នៅពេល៖**

ក) ប្រតិបត្តិករសកម្មភាពមីនដែលទើបទទួលបានអាជ្ញាប័ណ្ណប្រតិបត្តិការថ្មីៗ។

ខ) នៅពេលមានការផ្លាស់ប្តូរទ្រង់ទ្រាយធំលើថ្នាក់ដឹកនាំ និងរចនាសម្ព័ន្ធប្រតិបត្តិការ។

គ) លទ្ធផលនៃការត្រួតពិនិត្យ (តាមរយៈការវិភាគទិន្នន័យ ឬការចុះត្រួតពិនិត្យដល់ការដ្ឋាន) អាចនាំឱ្យយើងរកឃើញនូវចំណុចខ្វះខាតក្នុងការអនុវត្តរបស់ប្រតិបត្តិករ។

ឃ) ដើម្បីតាមដានមិនអនុលោមភាពដែលបានរកឃើញនាពេលកន្លងមក។

**ក្រុមត្រួតពិនិត្យគួរពិចារណា“ កាត់បន្ថយ” ភាពញឹកញាប់នៃការត្រួតពិនិត្យ នៅពេលដែល៖**

- ប្រតិបត្តិករសកម្មភាពមីន បានអនុវត្តសកម្មភាពដែលអាចទទួលយកបានក្នុងរយៈពេលកន្លង មក។
- និងមិនមានការផ្លាស់ប្តូរវិសាលភាពនៃសកម្មភាពរបស់ប្រតិបត្តិករសកម្មភាពមីនទេ។

## ៤.១.២ ប្រភេទនៃមិនអនុលោមភាព

មិនអនុលោមភាពគួរបែកចែកជា៖

ក) អ្វីដែលបានកើតឡើង - មិនអនុលោមភាពដែលបានកើតឡើងហើយ។

ខ) ឬអ្វីដែលទំនងនឹងកើតឡើង - អ្វីមួយដែលមិនទាន់បានកើតឡើង ប៉ុន្តែវាទំនងនឹងកើតឡើង។

## ៤.១.៣ កម្រិតនៃមិនអនុលោមភាព

ប្រព័ន្ធត្រួតពិនិត្យគួរកំណត់អំពីកម្រិតមិនអនុលោមភាព៖

**ក) កម្រិតស្រាល៖** ស្ថានភាពមិនសូវធ្ងន់ធ្ងរ រួមមាន ប៉ុន្តែអាចមានលើសពីនេះ៖

- អ្វីដែលកើតឡើងក្នុងកម្រិតមិនធ្ងន់ធ្ងរ។
- កង្វះខាតព័ត៌មាន ឬព័ត៌មានដែលមិនសូវសំខាន់។

- និងបញ្ហាដែលមានផលវិបាកប៉ះពាល់តិចតួចដល់ប្រសិទ្ធភាព ប៉ុន្តែវាមិនប៉ះពាល់ដល់ផលិតផល និងអ្នកទទួលផលឡើយ។

**ខ) កម្រិតធ្ងន់ធ្ងរមធ្យម៖** ជាស្ថានភាពធ្ងន់ធ្ងរមធ្យមរួមមាន ប៉ុន្តែអាចមានលើសពីនេះ៖

- ផ្នែកដ៏សំខាន់មួយនៃប្រព័ន្ធគ្រប់គ្រងគុណភាព មិនត្រូវបានអនុវត្ត។
- សកម្មភាពអ្វីមួយដែលប៉ះពាល់ដល់ការងារ ឬបុគ្គលិកក្នុងពេលប្រតិបត្តិការ ។
- បញ្ហាធ្ងន់ធ្ងរមធ្យមនឹងអាចកើតឡើងនៅពេលដែលផលិតផលមិនមានអនុលោមភាពប្រគល់ជូនអ្នកទទួលផល។
- បញ្ហាដែលផ្តល់ហានិភ័យដល់ប្រតិបត្តិករ បុគ្គលិក និងភាគីពាក់ព័ន្ធដ៏ទៃទៀត។

**គ) កម្រិតធ្ងន់ធ្ងរខ្លាំង**

មិនអនុលោមភាពដែលមានផលប៉ះពាល់ធ្ងន់ធ្ងរខ្លាំងភ្លាមៗទៅលើសុវត្ថិភាព បុគ្គលិក ភ្ញៀវ អ្នកទទួលផល អាជ្ញាធរ សាធារណជន ភាគីពាក់ព័ន្ធ ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថាន។

## ៤.២ ការត្រួតពិនិត្យ

អាជ្ញាធរមីន ត្រូវត្រួតពិនិត្យប្រតិបត្តិករសកម្មភាពមីន និងអង្គភាពចំណុះដើម្បីធ្វើឱ្យប្រាកដថាប្រព័ន្ធគ្រប់គ្រង និងនីតិវិធីប្រតិបត្តិការអនុលោមតាមប័ណ្ណទទួលស្គាល់ និងអាជ្ញាប័ណ្ណប្រតិបត្តិការ។ ការត្រួតពិនិត្យគួរធ្វើឡើងដោយអន្លើៗ មិនរំខាន និងមិនសូវប៉ះពាល់ដល់ពេលវេលាប្រតិបត្តិការ។

ការត្រួតពិនិត្យនៅការដ្ឋាន រួមមាន៖

- ពិនិត្យមើលការគ្រប់គ្រង ការិយាល័យកស្តការ និងរដ្ឋបាល ឬ មធ្យោបាយនានា រួមមានកន្លែងទុកដាក់រំសេវផ្ទុះ មធ្យោបាយព្យាបាល កន្លែងថែទាំសម្ភារៈ
- ត្រួតពិនិត្យទីតាំងអង្គភាពចំណុះ ការដ្ឋានប្រតិបត្តិការ និងកន្លែងគាំទ្រប្រតិបត្តិការ។
- ពិនិត្យមើលសកម្មភាពមីន នីតិវិធីធានាគុណភាព និងត្រួតពិនិត្យគុណភាពផ្ទៃក្នុង និងការកម្ទេចមីន /យុទ្ធភណ្ឌមិនទាន់ផ្ទុះ។
- ពិនិត្យមើលសកម្មភាពហ្វឹកហ្វឺន
- ត្រួតពិនិត្យប្រព័ន្ធគ្រប់គ្រងគុណភាពរបស់ប្រតិបត្តិករ
- បើអាច គួរពិនិត្យមើលការសាកល្បង និងវាយតម្លៃសម្ភារៈ។

### ៤.២.១ ការប្រមូលព័ត៌មាន

ក្រុមត្រួតពិនិត្យគួរសង្កេត ស្តាប់ និងសួរក្នុងអំឡុងពេលត្រួតពិនិត្យនៅការដ្ឋាន។ គួរសួរសំណួរបើកឱ្យបានច្រើន និងសំណួរបិទឱ្យតិច។

- សង្កេតមើល៖ សង្កេតមើលសកម្មភាព សមត្ថភាព និងការអនុវត្តតាមនីតិវិធី កត់ត្រា និងជៀសវាងធ្វើការសន្និដ្ឋានដោយគ្មានមូលដ្ឋាន។
- ស្តាប់៖ ស្តាប់ដោយយកចិត្តទុកដាក់ ពិនិត្យមើលការឆ្លើយតបទៅនឹងសំណួរ និងសួរដេញដោលបន្ថែម។
- សំណួរ៖ សួរសំណួរបើក (របៀបណា អ្វីគេ ហេតុអ្វី ពេលណា នរណា កន្លែងណា) និងសំណួរបែបជាសេណារីយ៉ូ ហើយធ្វើការផ្ទៀងផ្ទាត់ចម្លើយមកពីប្រភពផ្សេងៗ។

## ៤.២.២ ការគ្រប់គ្រង និងការគ្រប់គ្រងឯកសារ

ការត្រួតពិនិត្យគួរមានការពិនិត្យមើលលើការគ្រប់គ្រងឯកសារសកម្មភាពមីន ឧទាហរណ៍៖ វិញ្ញាបនបត្រ ឯកសារបណ្តុះបណ្តាល ឯកសារធានារ៉ាប់រង និងឯកសារបញ្ជាក់សុខភាព។ ឯកសាររដ្ឋបាលទូទៅ ឯកសារបុគ្គលិកម្នាក់ៗ ឯកសារសម្ងាត់ផ្ទៃក្នុងរបស់អង្គភាព មិនគួរពិនិត្យមើលឡើយ។

ប៉ាន់គំរូឯកសារដែលបានជ្រើសរើសគួរតែជាតំណាងឱ្យឯកសារខាងលើ។

## ៤.២.៣ អនុលោមតាមស្តង់ដា បទដ្ឋានប្រតិបត្តិការ និងនីតិវិធី

ការត្រួតពិនិត្យគួររកឱ្យឃើញអនុលោមភាព និងកម្រិតមិនអនុលោមភាពដោយធៀបទៅនឹងស្តង់ដាបទដ្ឋានប្រតិបត្តិការ និងនីតិវិធីនីមួយៗ។

អនុលោមភាពបង្ហាញថា កម្រិតតម្រូវការ វិធីសាស្ត្រ ឬលក្ខណៈបច្ចេកទេស អនុលោមទៅតាមស្តង់ដាដែលបានកំណត់។

## ៤.២.៤ ការដ្ឋានសុវត្ថិភាព

ការផ្តល់បរិយាកាសការងារដែលមានសុវត្ថិភាពរួមមាន ការរៀបចំការដ្ឋានដោយដាក់ស្លាកសញ្ញាសម្គាល់តំបន់គ្រោះថ្នាក់ ដើម្បីគ្រប់គ្រងការធ្វើដំណើររបស់អ្នកដោះមីន ភ្ញៀវទស្សនកិច្ច និងប្រជាពលរដ្ឋមូលដ្ឋាន ដោយគោរពតាមចម្ងាយសុវត្ថិភាព និងផ្តល់ការព្យាបាល ការសង្គ្រោះ និងការជម្លៀសជនរងគ្រោះដ៏មានប្រសិទ្ធភាព។ នីតិវិធីធ្វើការនៅការដ្ឋានត្រូវតែអនុលោមទៅតាមស្តង់ដាជាតិ ហើយត្រូវបានអនុវត្តទៅតាមបទដ្ឋានប្រតិបត្តិការ។ អាជ្ញាធរមីនត្រូវធ្វើការវាយតម្លៃពីលក្ខណៈសមស្រប នៃការរៀបចំការដ្ឋាន និងនីតិវិធីសុវត្ថិភាព ហើយសន្និដ្ឋានថា តើការអនុវត្តតាមនីតិវិធីមានប្រសិទ្ធភាពយ៉ាងណា។

## ៤.២.៥ ការគាំទ្រផ្នែកពេទ្យ

ការបង្កើតផ្នែកពេទ្យដែលមានសមត្ថភាពគ្រប់គ្រាន់ ទាមទារឱ្យមានផែនការច្បាស់លាស់ បុគ្គលិកដែលមានសមត្ថភាព និងមានបរិក្ខារពេទ្យគ្រប់គ្រាន់ដើម្បីផ្តល់ការព្យាបាលដែលមានប្រសិទ្ធភាព។

អាជ្ញាធរមីនត្រូវធ្វើការវាយតម្លៃផ្នែកពេទ្យនៅនឹងការដ្ឋានដូចជា សមត្ថភាពបុគ្គលិកពេទ្យ បរិក្ខារ ពេទ្យ សម្ភារៈពេទ្យ ថ្នាំពេទ្យ និងរថយន្តសង្គ្រោះ។ ត្រូវពិនិត្យមើលផងដែរនូវនីតិវិធីព្យាបាល សង្គ្រោះ បន្ទាន់ និងជម្លៀសជនរងគ្រោះ។ ក្រុមត្រួតពិនិត្យគួរស្នើសុំឱ្យប្រតិបត្តិករសកម្មភាពមីនធ្វើការសាក ល្បង ព្យាបាល និងជម្លៀសជនរងគ្រោះយ៉ាងហោចណាស់បីខែម្តង។

## ៤.២.៦ ការរក្សាទុក ការដឹកជញ្ជូន និងការប្រើប្រាស់គ្រឿងផ្ទុះ

ការផ្តល់បរិយាកាសការងារដែលមានសុវត្ថិភាពរួមមាន ការរក្សាទុក ការដឹកជញ្ជូន ការប្រើប្រាស់គ្រឿងផ្ទុះ និងសម្ភារៈគ្រឿងផ្ទុះ។ ការធ្វើដូច្នេះទាមទារឱ្យមានឃ្លាំងស្តុកគ្រឿងផ្ទុះ សម្ភារៈគ្រប់គ្រាន់ រថយន្ត និងនីតិវិធីគ្រប់គ្រងគ្រឿងផ្ទុះ។ អាជ្ញាធរមីនត្រូវធ្វើការវាយតម្លៃទៅលើលក្ខណៈសមស្រប នៃនីតិវិធីរក្សាទុក ដឹកជញ្ជូន ប្រើប្រាស់គ្រឿងផ្ទុះ ហើយសន្និដ្ឋានថា តើការអនុវត្តតាមនីតិវិធីមានប្រសិទ្ធភាពយ៉ាងណា។ អាជ្ញាធរមីនត្រូវប្រាកដថាប្រតិបត្តិករសកម្មភាពមីន មាននីតិវិធីគ្រប់គ្រងគ្រឿងផ្ទុះ និងសម្ភារៈគ្រឿងផ្ទុះ ហើយធ្វើឱ្យប្រាកដថា នីតិវិធីទាំងនោះត្រូវបានអនុវត្តយ៉ាងខ្ជាប់ខ្ជួន។

## ៤.២.៧ ការស៊ើបអង្កេតឧប្បត្តិហេតុ និងគ្រោះថ្នាក់

អាជ្ញាធរមីនត្រូវធ្វើការសិក្សាទៅលើលក្ខណៈសមស្រប នៃនីតិវិធីរាយការណ៍ក្រោយឧបទ្ទវហេតុ និងនីតិវិធីស៊ើបអង្កេត។

## ៤.២.៨ ឧបករណ៍

អាជ្ញាធរមីនត្រូវសិក្សាអំពីប្រសិទ្ធភាពនៃឧបករណ៍។ ការសិក្សានេះរួមមាន ការពិនិត្យមើលសម្ភារៈសំខាន់ៗខ្លះៗ (ដូចជាម៉ាស៊ីនរាវរកមីន / យុទ្ធភណ្ឌមិនទាន់ផ្ទុះ) និងពិនិត្យមើលកំណត់ត្រាថែទាំ ជួសជុល និងកែសម្រួលឧបករណ៍។ អាជ្ញាធរមីនក៏ត្រូវពិនិត្យមើលរោងជាង និងឧបករណ៍ជួសជុលផងដែរ។

## ៤.២.៩ សកម្មភាពមីន

អាជ្ញាធរមីនត្រូវសង្កេតមើលសកម្មភាពមីន របស់ប្រតិបត្តិករដើម្បីធានាថា ការអនុវត្តនោះស្របតាមបទដ្ឋានប្រតិបត្តិការ។ នៅពេលពិនិត្យមើលការបោសសម្អាតមីនជាលក្ខណៈបច្ចេកទេសដូចជា ការប្រើប្រាស់សត្វ ឬគ្រឿងចក្រ អាជ្ញាធរមីនត្រូវអញ្ជើញបុគ្គលិកដែលមានជំនាញបច្ចេកទេសចូលរួមផងដែរ។

## ៤.២.១០ ការត្រួតពិនិត្យមើលទិដ្ឋភាពបរិស្ថាន

ដំណើរការសកម្មភាពមីន អាចនឹងជះផលប៉ះពាល់អវិជ្ជមានលើបរិស្ថាន (ការដោះមីនដោយដៃ និងគ្រឿងចក្រ ការកម្ទេចគ្រាប់ ការបោលកាកសំណល់។ល។)។ ក្រុមត្រួតពិនិត្យគួរពិនិត្យមើលផែនការគ្រប់គ្រងបរិស្ថានអនុលោមតាមស្តង់ដាជំពូក២០ ស្តីពីការគ្រប់គ្រងបរិស្ថានក្នុងសកម្មភាពមីន។

## ៤.២.១១ របាយការណ៍

ក្រុមត្រួតពិនិត្យអាជ្ញាធរមីន ត្រូវពន្យល់សង្ខេបពីលទ្ធផលនៃការរកឃើញដល់ប្រធានការដ្ឋាន ឬអង្គភាពចំណុះមុនពេលចាកចេញពីការដ្ឋាន ដោយសង្កត់ធ្ងន់ទៅលើកំហុសទាំងឡាយណាដែលទាក់ទងទៅនឹងសុវត្ថិភាព។

ការរកឃើញរបស់ក្រុមត្រួតពិនិត្យត្រូវកត់ត្រាក្នុងរបាយការណ៍គ្រប់គ្រងគុណភាព។ ពេលត្រួតពិនិត្យប្រតិបត្តិការបោសសម្អាតមីន/គ្រាប់ របាយការណ៍ចុះត្រួតពិនិត្យនៅការដ្ឋានត្រូវផ្ញើជូនប្រធានអង្គភាពចំណុះដើម្បីរក្សាទុកឯកសារចម្ការមីន/គ្រាប់។ ប្រធានក្រុមត្រួតពិនិត្យអាជ្ញាធរមីនត្រូវពិភាក្សា និងឯកភាពជាមួយប្រធានការដ្ឋាននូវកំហុសដែលរកឃើញ និងដំណោះស្រាយចំពោះកំហុសនោះ។

ត្រូវធ្វើរបាយការណ៍ត្រួតពិនិត្យជូនប្រតិបត្តិករ ហើយរបាយការណ៍នោះត្រូវមានភាពច្បាស់លាស់ ជាពិសេសប្រសិនបើមានការរិះគន់ប៉ះពាល់ដល់ការគ្រប់គ្រង ឬសកម្មភាពប្រតិបត្តិការរបស់ប្រតិបត្តិករសកម្មភាពមីន។

## ៤.២.១២. ប្រជុំបិទបញ្ចប់ការត្រួតពិនិត្យ

គួរមានការប្រជុំបិទបញ្ចប់ការត្រួតពិនិត្យមុនពេលចាកចេញពីការដ្ឋាន ដើម្បីធានាថាអ្វីដែលបានរកឃើញ និងការបូកសរុបលទ្ធផលត្រួតពិនិត្យត្រូវបានពន្យល់ ហើយព្រមព្រៀងគ្នាលើសកម្មភាពត្រូវតាមដាន ឬអនុវត្តបន្តដល់អ្នកគ្រប់គ្រងការដ្ឋាន។ ការប្រជុំបិទបញ្ចប់ការត្រួតពិនិត្យជាឱកាសមួយដើម្បីរកភាពមិនចុះសម្រុងគ្នា និងស្វែងរកដំណោះស្រាយរួមរវាងក្រុមត្រួតពិនិត្យ និងប្រតិបត្តិករ។

**ការប្រជុំបិទបញ្ចប់គួរមានៈ**

- អរគុណដល់អ្នកគ្រប់គ្រងការដ្ឋានសម្រាប់កិច្ចសហប្រតិបត្តិការរបស់ពួកគេ។
- បញ្ជាក់ថា ការរកមិនឃើញបញ្ហាមិនមែនមានន័យថាគ្មានបញ្ហានោះទេ - វានៅតែជាការទទួលខុសត្រូវរបស់ប្រតិបត្តិករសកម្មភាពមីនដើម្បីគ្រប់គ្រងគុណភាពនៃការងាររបស់ខ្លួន។
- បង្ហាញភាពមិនអនុលោមដែលបានរកឃើញ និងយល់ព្រមអនុវត្តការកែតម្រូវ។
- អះអាងថាអ្វីដែលបានរកឃើញនឹងត្រូវរក្សាជាការសម្ងាត់រវាងក្រុមត្រួតពិនិត្យ និងប្រតិបត្តិករសកម្មភាពមីន។
- ព្រមព្រៀងលើសកម្មភាពតាមដានអនុវត្តបន្ត និង
- ឆ្លើយនឹងសំណួរផ្សេងៗដែលមានក្នុងអំឡុងពេលត្រួតពិនិត្យនៅការដ្ឋាន។

## ៤.៣ ការវិភាគលើមូលហេតុ

មានការយល់ដឹងពីមូលហេតុមិនអនុលោមភាពដែលបានកើតឡើង ឬបម្រុងនឹងកើតឡើងជាមូលដ្ឋានសំខាន់ក្នុងការគ្រប់គ្រងអង្គការសកម្មភាពមីនប្រកបដោយគុណភាពខ្ពស់។ ក្រុមត្រួតពិនិត្យគួរធានាថាមូលហេតុមិនអនុលោមភាពត្រូវបានកំណត់ ពន្យល់ និងព្រមព្រៀងគ្នាដើម្បីអនុវត្ត សកម្មភាពកែតម្រូវឱ្យបានសមស្រប។

កំហុសទាំងបួនប្រភេទរួមមាន កំហុសភ្លាំងភ្លាត់ (Slip) កំហុសភ្លេចភ្លាំង (Lapse) កំហុសអចេតនា (Mistake) និងការបំពាន (Violation) អាចមានប្រយោជន៍ក្នុងការវិភាគអំពីមូលហេតុបញ្ហា

## ៤.៤ ឆ្លើយតបនឹងមិនអនុលោមភាព

ប្រតិបត្តិករសកម្មភាពមីន ត្រូវដោះស្រាយរាល់ភាពមិនអនុលោមដែលបានរកឃើញដោយក្រុមត្រួតពិនិត្យ។ សកម្មភាពឆ្លើយតបទៅនឹងភាពមិនអនុលោម គួររាប់បញ្ចូលទាំងសកម្មភាពកែតម្រូវ (បញ្ឈប់មូលហេតុដែលបង្ករឱ្យមានភាពមិនអនុលោម) និងការពារ/ទប់ស្កាត់ (បញ្ឈប់មូលហេតុដែលអាចបង្ករឱ្យមានភាពមិនអនុលោម) ។

គួរតាមដានជាប្រចាំបន្ទាប់ពីបានកំណត់បានរកឃើញភាពមិនអនុលោម ដើម្បីបញ្ជាក់ថាសកម្មភាពសមស្របត្រូវបានធ្វើឡើងដើម្បីកែស្ថានការណ៍ និងការពារកុំឱ្យកើតមានម្តងទៀត។ ការតាមដានអាចធ្វើឡើងតាមរយៈការផ្តល់ភស្តុតាងជាឯកសារដល់ក្រុមត្រួតពិនិត្យ ឬការចុះត្រួតពិនិត្យដល់ការដ្ឋានតាមដែលអាចធ្វើបាន។

អាជ្ញាធរមីនត្រូវអញ្ជើញប្រតិបត្តិករសកម្មភាពមីន ឱ្យធ្វើបទបង្ហាញអំពីនីតិវិធីគ្រប់គ្រង ឬកិច្ចប្រតិបត្តិការត្រឹមត្រូវ ថាតើវាអនុលោមតាមតម្រូវការដែលបានចែង ប្រសិនបើបញ្ហានោះមានលក្ខណៈធ្ងន់ធ្ងរ។

# ៥. ក្រុមត្រួតពិនិត្យ - កាតព្វកិច្ចទូទៅ

## ៥.១ ទូទៅ

នាយកដ្ឋានបទបញ្ញត្តិ និងត្រួតពិនិត្យអាជ្ញាធរមីនទទួលខុសត្រូវក្នុងការត្រួតពិនិត្យ តាមដានធ្វើអធិការកិច្ច និងវាយតម្លៃលើដំណើរការអនុវត្តស្តង់ដាជាតិ ចំពោះប្រតិបត្តិករសកម្មភាពមីនទាំងអស់នៅកម្ពុជា។ នាយកដ្ឋានត្រូវមានបុគ្គលិកជំនាញ និងសម្ភារៈគ្រប់គ្រាន់ដើម្បីត្រួតពិនិត្យប្រតិបត្តិករ និងអង្គភាពចំណុះ ដែលអនុវត្តសកម្មភាពក្នុងលក្ខណៈសមស្រប និងមានប្រសិទ្ធភាព ។

នាយកដ្ឋានត្រូវមានឯកសារចាំបាច់ដែលពិពណ៌នាអំពីការទទួលខុសត្រូវ នីតិវិធីដែលត្រូវប្រើប្រាស់ក្នុងដំណើរការត្រួតពិនិត្យ និងវិសាលភាពបច្ចេកទេសនៃសកម្មភាពរបស់ខ្លួន។ អាជ្ញាធរមីនត្រូវកំណត់ឱ្យបានច្បាស់អំពីភាពទំនាក់ទំនងគ្នារវាងប័ណ្ណទទួលស្គាល់ អាជ្ញាប័ណ្ណប្រតិបត្តិការ និងមុខងារត្រួតពិនិត្យ។

## ៥.២ ផ្នែកត្រួតពិនិត្យ

នាយកដ្ឋានបទបញ្ញត្តិ និងត្រួតពិនិត្យត្រូវមានផ្នែកបច្ចេកទេសដែលមានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តមុខងារ បានយ៉ាងឆាប់រហ័ស និងពេញចិត្ត។ នាយកដ្ឋានត្រូវមានប្រធានគ្រប់គ្រងបច្ចេកទេស ម្នាក់ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងមានបទពិសោធន៍ក្នុងដំណើរការត្រួតពិនិត្យ និងមានការទទួលខុសត្រូវទូទៅ ធានាថាសកម្មភាពត្រួតពិនិត្យត្រូវបានអនុវត្តស្របតាមស្តង់ដាជាតិ និងគោលការណ៍បច្ចេកទេសពាក់ព័ន្ធនានាផ្សេងទៀត។ ប្រធានគ្រប់គ្រងបច្ចេកទេស គួរតែជាបុគ្គលិកអចិន្ត្រៃយ៍ ប៉ុន្តែអាចជាអ្នកពិគ្រោះយោបល់ក៏បានដែរ។

នាយកដ្ឋានត្រូវមានចំនួនបុគ្គលិកអចិន្ត្រៃយ៍គ្រប់គ្រាន់ ដែលមានជំនាញគ្រប់គ្រាន់ដើម្បីអនុវត្តមុខងារ។

## ៥.៣ ប្រព័ន្ធគ្រប់គ្រង

នាយកដ្ឋានបទបញ្ញត្តិ និងត្រួតពិនិត្យត្រូវកំណត់ និងចងក្រងឯកសារប្រព័ន្ធគ្រប់គ្រង និងនីតិវិធីដែលធានាថាគោលការណ៍គ្រប់គ្រងត្រូវបានពន្យល់ និងនីតិវិធីត្រូវបានអនុវត្ត និងរក្សានៅគ្រប់កម្រិតទាំងអស់នៅក្នុងផ្នែកត្រួតពិនិត្យ។ នៅពេលដែលប្រព័ន្ធ និងនីតិវិធីប៉ះពាល់ដល់ការអនុវត្តកម្មវិធីសកម្មភាពមីន ទំនាក់ទំនងរវាងនាយកដ្ឋាន និងប្រតិបត្តិករសកម្មភាពមីនគួរត្រូវបានព្រមព្រៀងគ្នា ហើយបង្កើតជាផ្នែកនៃការរៀបចំកិច្ចសន្យា។

នាយកដ្ឋានត្រូវបង្កើត និងថែរក្សានីតិវិធីសម្រាប់ការត្រួតពិនិត្យតាមការដ្ឋាន។

នាយកដ្ឋានត្រូវរៀបចំ និងរក្សាទុកកំណត់ត្រានៃការត្រួតពិនិត្យការដ្ឋានទាំងអស់ និងរាល់ព័ត៌មានទាំងអស់ងាយនឹងយល់ ហើយបកស្រាយបាន។ រាល់កំណត់ត្រាទាំងអស់ត្រូវរក្សាទុកក្នុងរយៈពេលយ៉ាងតិចប្រាំឆ្នាំ ដោយមានសុវត្ថិភាព និងរក្សាបាននូវទំនុកចិត្តជូនអ្នកដាក់ពាក្យសុំ លើកលែងតែមានការតម្រូវខាងផ្នែកច្បាប់។

## ៥.៤ ឯករាជ្យភាព អព្យាក្រិតភាព និងសុចរិតភាព

បុគ្គលិកនាយកដ្ឋានបទបញ្ញត្តិ និងត្រួតពិនិត្យ មិនត្រូវជាប់ពាក់ព័ន្ធជាមួយក្រុមហ៊ុនពាណិជ្ជកម្ម ហិរញ្ញវត្ថុ ឬការគាបសង្កត់ផ្សេងៗ ដែលអាចជះឥទ្ធិពលលើការវិនិច្ឆ័យរបស់ខ្លួន។ គោលការណ៍ច្បាប់ និងនីតិវិធីនានានឹងត្រូវយកមកអនុវត្ត ដើម្បីធានាថាបុគ្គលិក ឬស្ថាប័នក្រៅពីនាយកដ្ឋាន មិនអាចមានអានុភាពលើលទ្ធផលនៃការស៊ើបអង្កេត ការធ្វើអធិការកិច្ច និងការវាយតម្លៃដែលអនុវត្តដោយក្រុមត្រួតពិនិត្យ។

ក្រុមត្រួតពិនិត្យ និងបុគ្គលិករបស់ខ្លួន មិនត្រូវជាប់ពាក់ព័ន្ធក្នុងសកម្មភាពណាមួយ ដែលនាំទៅដល់ការខ្វែងគំនិតលើឯករាជ្យភាពនៃការវិនិច្ឆ័យ និងសុចរិតភាពដែលមានការពាក់ព័ន្ធនឹងការពិនិត្យមើល អធិការកិច្ច និងការវាយតម្លៃ ជាពិសេសពួកគេមិនត្រូវពាក់ព័ន្ធដោយផ្ទាល់ជាមួយក្រុមហ៊ុន/អង្គការដែលរចនាម៉ូដ ផលិត ផ្គត់ផ្គង់ បំពាក់ ប្រើប្រាស់ សេវាថែទាំ ឬផលិតសម្ភារៈសម្រាប់ប្រតិបត្តិករដែលធ្វើប្រតិបត្តិការសកម្មភាពមីន ឬវិស័យដែលប្រហាក់ប្រហែលគ្នានោះទេ។

ភាគីពាក់ព័ន្ធទាំងអស់ ត្រូវមានលទ្ធភាពក្នុងការទទួលយកសេវាកម្មពីនាយកដ្ឋាន។ នីតិវិធីនានាដែលអង្គភាពធ្វើប្រតិបត្តិការ ត្រូវអនុវត្តតាមលក្ខណៈមិនរើសអើង និងបកស្រាយអំពីយេនឌ័រ។

នាយកដ្ឋានត្រូវធានាការសម្ងាត់នៃព័ត៌មាន ដែលបានទទួលនៅក្នុងសកម្មភាពត្រួតពិនិត្យរបស់ខ្លួន ។ សិទ្ធិជាម្ចាស់កម្មសិទ្ធិត្រូវបានការពារ ។

## ៦. ការទទួលខុសត្រូវ

### ៦.១ អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកម្ចាត់មីន និងសង្គ្រោះជនពិការដោយសារមីន

- បង្កើតប្រព័ន្ធត្រួតពិនិត្យប្រតិបត្តិករសកម្មភាពមីន ដោយបំពេញទៅតាមនីតិវិធីនានា សម្រាប់ប័ណ្ណទទួលស្គាល់ និងអាជ្ញាប័ណ្ណប្រតិបត្តិការ ស្តង់ដាសកម្មភាពកម្ចាត់មីនកម្ពុជា និងច្បាប់ផ្សេងទៀត។
- បង្កើតស្តង់ដាជាតិ និងផ្តល់គោលការណ៍បច្ចេកទេសសម្រាប់ការត្រួតពិនិត្យប្រតិបត្តិករសកម្មភាពមីន។
- បង្កើត និងបណ្តុះបណ្តាលក្រុមត្រួតពិនិត្យ។
- ឃ្លាំមើលការងាររបស់អង្គភាពត្រួតពិនិត្យ ដើម្បីធានាថាប្រព័ន្ធត្រួតពិនិត្យដែលកំពុងអនុវត្តមានយុត្តិធម៌ និងសមធម៌ បកស្រាយនៃឌីវ ដោយមិនរំខាន ឬបង្អាក់ដល់គម្រោងសកម្មភាពមីន។
- អនុវត្តដំណើរការប្តឹងតវ៉ាដូចបានរៀបរាប់លម្អិតក្នុងស្តង់ដាជំពូក២ ការផ្តល់ប័ណ្ណទទួលស្គាល់ និងអាជ្ញាប័ណ្ណប្រតិបត្តិការ នៅពេលប្រតិបត្តិករសកម្មភាពមីនដាក់បណ្តឹងតវ៉ា។
- ធានាថាសកម្មភាពកែតម្រូវសមស្រប ត្រូវបានអនុវត្តតាមអនុសាសន៍របស់ក្រុមត្រួតពិនិត្យ។
- ផ្តល់ការបណ្តុះបណ្តាលដល់ក្រុមត្រួតពិនិត្យ ដើម្បីអនុវត្តការត្រួតពិនិត្យឱ្យមានមានប្រសិទ្ធភាព
- រៀបចំផែនការត្រួតពិនិត្យ និងកាលវិភាគដើម្បីឱ្យនាយកដ្ឋានត្រួតពិនិត្យប្រតិបត្តិករសកម្ម ភាពមីន និងអង្គភាពចំណុះប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។
- រៀបចំឯកសារស្របច្បាប់ទាក់ទងនឹងដំណើរការត្រួតពិនិត្យ និងអធិការកិច្ចនៅការដ្ឋានផ្តល់ជូនភាគីដែលមានចំណាប់អារម្មណ៍ ។

### ៦.២ ប្រតិបត្តិករសកម្មភាពមីន

- អនុវត្តការគ្រប់គ្រងទូទៅ ការគ្រប់គ្រងគុណភាព និងនីតិវិធីប្រតិបត្តិការដែលមានគោលបំណងបោសសម្អាតដីស្របតាមតម្រូវការ ដែលបានបញ្ជាក់នៅក្នុងកិច្ចសន្យាបោសសម្អាត ឬកិច្ចព្រមព្រៀងជាផ្លូវការផ្សេងទៀត ដោយអនុលោមតាមស្តង់ដាសកម្មភាពកម្ចាត់មីនកម្ពុជា។
- ធានាថាផែនការប្រតិបត្តិការបោសសម្អាត ត្រូវបានពិគ្រោះយោបល់ជាមួយអាជ្ញាធរមីនស្របតាមស្តង់ដាជាតិ និងឆ្លើយតបអាទិភាពថ្នាក់ជាតិ។
- ថែរក្សា និងរៀបចំឱ្យមានឯកសារ របាយការណ៍ កំណត់ត្រា និងទិន្នន័យផ្សេងៗទៀតស្តីពីសកម្មភាពបោសសម្អាតមីនផ្តល់ជូននាយកដ្ឋានត្រួតពិនិត្យ។
- អនុញ្ញាតិឱ្យអាជ្ញាធរមីន ចុះត្រួតពិនិត្យគ្រប់ការដ្ឋាន អគារ និងកន្លែងផ្សេងទៀតដែលចាំបាច់ដែលជាផ្នែកមួយនៃតម្រូវការត្រួតពិនិត្យ។

- គោរព និងអនុវត្តតាមការណែនាំរបស់ក្រុមត្រួតពិនិត្យក្នុងករណីមានភាពមិនអនុលោមធ្ងន់ធ្ងរ។

### ៦.៣ ម្ចាស់ជំនួយ និងអ្នកពាក់ព័ន្ធផ្សេងទៀត

ប្រទេសម្ចាស់ជំនួយ ចាំបាច់ត្រូវដាក់បញ្ចូលព័ត៌មានលម្អិតនៃតម្រូវការត្រួតពិនិត្យថ្នាក់ជាតិនៅពេលរៀបចំកិច្ចសន្យា ឬកិច្ចព្រមព្រៀងជាផ្លូវការផ្សេងៗ។ ម្ចាស់ជំនួយត្រូវមានការទទួលខុសត្រូវផងដែរ ដើម្បីធានាថាផែនការបោសសម្អាតមីនត្រូវមានការសម្របសម្រួលជាមួយអាជ្ញាធរមីន និងឆ្លើយតបទៅនឹងគោលការណ៍ និងអាទិភាពថ្នាក់ជាតិ។

ថ្ងៃច័ន្ទ ៧ រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែតុលា ឆ្នាំ២០២២

**អគ្គលេខាធិការ**

**ព្រុំ សុភមង្គល**

## ឧបសម្ព័ន្ធ ១៖ ភ្ជាប់មកជាមួយទម្រង់ត្រួតពិនិត្យ (១២)

ទម្រង់ ០១: ទម្រង់វាយតម្លៃការគ្រប់គ្រងគុណភាពជំរុំស្នាក់នៅអ្នកដោះមីន
ទម្រង់ ០២: ទម្រង់វាយតម្លៃការគ្រប់គ្រងគុណភាពកិច្ចប្រតិបត្តិការសត្វហិតមីន/គ្រាប់
ទម្រង់ ០៣: ទម្រង់វាយតម្លៃការគ្រប់គ្រងគុណភាពកិច្ចប្រតិបត្តិការកំទេចគ្រឿងផ្ទុះ
ទម្រង់ ០៤: ទម្រង់វាយតម្លៃការគ្រប់គ្រងគុណភាពលើការទុកដាក់គ្រឿងផ្ទុះ
ទម្រង់ ០៥: ទម្រង់វាយតម្លៃការគ្រប់គ្រងគុណភាពកិច្ចប្រតិបត្តិការបោសសម្អាតមីន/គ្រាប់
ទម្រង់ ០៦: ទម្រង់វាយតម្លៃការគ្រប់គ្រងគុណភាពកិច្ចប្រតិបត្តិការគ្រឿងចក្រ័ក
ទម្រង់ ០៧: ទម្រង់វាយតម្លៃការគ្រប់គ្រងគុណភាពការសង្គ្រោះបឋម
ទម្រង់ ០៨: ទម្រង់វាយតម្លៃការគ្រប់គ្រងគុណភាពលើការស្រាវជ្រាវមូលដ្ឋាន NTS
ទម្រង់ ០៩: ទម្រង់ត្រួតពិនិត្យគុណភាព
ទម្រង់ ១០: ទម្រង់ត្រួតពិនិត្យគុណភាពពហុកោណថ្មី
ទម្រង់ ១១: ទម្រង់ត្រួតពិនិត្យសារមន្ទីមីន/គ្រាប់យុទ្ធភ័ណ្ឌ
ទម្រង់ ១២: វាយតម្លៃការអប់រំបញ្ហាមីន

## ឧបសម្ព័ន្ធ ២៖ បញ្ជីណែនាំលើការកម្រឹតមិនអនុលោមភាព

# ឧបសម្ព័ន្ធ ៣៖ ការណែនាំស្តីពីការត្រួតពិនិត្យគុណភាពដីដែលបានកាត់បន្ថយ

## ១. ការអនុវត្តការត្រួតពិនិត្យដីដែលបានកាត់បន្ថយ

មុនពេលអនុវត្តការត្រួតពិនិត្យដីដែលបានកាត់បន្ថយ ក្រុមត្រួតពិនិត្យ និងអ្នកធ្វើការសម្រេចចិត្តដែលពាក់ព័ន្ធគួរ៖

- ធ្វើការត្រួតពិនិត្យរាល់ព័ត៌មានទាំងអស់ ដែលទទួលបានក្នុងអំឡុងពេលស្រាវជ្រាវមិនបច្ចេកទេស ស្រាវជ្រាវបច្ចេកទេស និងការបោសសម្អាតនៅការដ្ឋាន។
- ពិចារណាថា តើការត្រួតពិនិត្យដីដែលបានកាត់បន្ថយនៅការដ្ឋានមានភាពសមស្រប និងចាំបាច់។
- ប្រសិនបើចាំបាច់ត្រូវត្រួតពិនិត្យដីដែលបានកាត់បន្ថយ កំណត់ទំហំដែលត្រូវត្រួតពិនិត្យផ្អែកលើលទ្ធផលបានមកពីការស្រាវជ្រាវមិនបច្ចេកទេស ស្រាវជ្រាវបច្ចេកទេស និងការបោសសម្អាត និង
- កំណត់ទំហំផ្ទៃដីត្រួតពិនិត្យ ដែលមានភ័ស្តុតាងមីន/គ្រាប់ ក៏ដូចជាទីតាំង/ចំណុចបញ្ចប់ការគំរាមដែលពាក់ព័ន្ធនានា។

## ២. ការពិនិត្យគុណភាពដី

ក្រុមត្រួតពិនិត្យគួរជ្រើសរើសទីតាំងដែលត្រូវត្រួតពិនិត្យគុណភាព ដោយមានការព្រមព្រៀងពីប្រតិបត្តិករសកម្មភាពមីន ទីតាំងនោះឱ្យឈ្មោះថា“ ដីឡូ” ។

ក្រុមត្រួតពិនិត្យគួររៀបចំផែនការត្រួតពិនិត្យគុណភាពដីស្របតាមតម្រូវការ ដែលបានព្រមព្រៀងគ្នា។ ទីតាំងត្រូវត្រួតពិនិត្យគុណភាពគួរ "កំណត់ទីតាំង" តំបន់ទាំងនោះជាកម្មវត្ថុនៃការស្រាវជ្រាវបច្ចេកទេស ឬការបោសសម្អាត។ មិនត្រូវគិតទុកជាមុននូវទីតាំងដែលត្រូវត្រួតពិនិត្យគុណភាព។ ការជ្រើសរើសទីតាំងត្រួតពិនិត្យគុណភាពផ្អែកទៅតាមកាលៈទេសៈ គួរផ្តោតលើទីតាំងណាដែលអាចមានបញ្ហា ឬទីតាំងជាអន្លើៗក្នុងការលើកទឹកចិត្ត និងពង្រឹងការងារអ្នកដោះមីនថា មានអ្នកត្រួតពិនិត្យតាមក្រោយ។

ត្រូវធ្វើការត្រួតពិនិត្យគុណភាពដីក្នុងអំឡុងពេលកាត់បន្ថយផ្ទៃដី ដែលក្រុមត្រួតពិនិត្យ និងប្រតិបត្តិករសកម្មភាពមីនព្រមព្រៀងគ្នា។ ការត្រួតពិនិត្យគុណភាពដីបោសសម្អាត មានគោលបំណងដើម្បីពង្រឹងទម្លាប់ល្អនៃការងាររបស់អ្នកដោះមីន ដូច្នេះការត្រួតពិនិត្យផ្នែកខ្លះនៃទីតាំងដែលបានបោសសម្អាតរួច ជាសារសម្រាប់ប្រតិបត្តិករពង្រឹងការងាររបស់បុគ្គលិកថា គុណភាពការងារមិនល្អនឹងអាចត្រូវបានរកឃើញដោយក្រុមត្រួតពិនិត្យ។

## ៣. ឧបករណ៍ និងវិធីសាស្ត្រ

ការត្រួតពិនិត្យគុណភាពដីទាំងអស់គួរធ្វើឡើងដោយប្រើឧបករណ៍ និងវិធីសាស្ត្រដែលអាចរកឃើញវត្ថុមានកម្ទេចលោហធាតុដែលកំណត់នូវទំហំ និងជម្រៅអប្បបរមាក្នុងការបោសសម្អាត។ គួរធ្វើតេស្តម៉ាស៊ីនរាវមីន ពីសមត្ថភាពក្នុងការរាវរកកម្ទេចដែក មុន និងក្រោយពេលត្រួតពិនិត្យគុណភាពដី ដើម្បីបញ្ជាក់ពីភាពសមស្របនៃការងារ។

គួរកំណត់ទំហំផ្ទៃដីដែលត្រូវត្រួតពិនិត្យក្នុងកម្រិតអប្បបរមា សមស្របតាមកាលៈទេសៈ និងស្ថានភាពទីតាំង ដែលជាគោលបំណងនៃការត្រួតពិនិត្យគុណភាព។ ការកម្រិតផ្ទៃដី១%ដើម្បីត្រួតពិនិត្យសមស្របក្នុងកាលៈទេសៈទូទៅ ប៉ុន្តែអាចបង្កើនទំហំត្រួតពិនិត្យបានក្នុងករណីបង្កើនទំនុកចិត្តដល់សហគមន៍ ឬប្រើប្រាស់ជាឧបករណ៍ដើម្បីលើកទឹកចិត្ត ដល់ប្រតិបត្តិករសកម្មភាពមីនឱ្យការអនុវត្តទូទៅប្រសើរជាងពេលមុន។

គួរធ្វើការត្រួតពិនិត្យគុណភាពដីដោយអន្លើៗលើគ្រប់ផ្នែកទាំងអស់ ដែលបានស្រាវជ្រាវបច្ចេកទេស។ ក្រុមត្រួតពិនិត្យអាចជ្រើសរើសទីតាំងតែមួយកន្លែងនៅក្នុងការដ្ឋានដើម្បីត្រួតពិនិត្យ ប៉ុន្តែមិនគួរទុកចោលកន្លែងទាំងអស់នោះដោយមិនមានការត្រួតពិនិត្យទេ។

## ៤. ឧបករណ៍ត្រួតពិនិត្យ

ក្រុមត្រួតពិនិត្យអាចប្រើប្រាស់ឧបករណ៍របស់ខ្លួន ឬឧបករណ៍របស់ប្រតិបត្តិករសកម្មភាពមីន ការត្រួតពិនិត្យគុណភាពស្ថិតក្រោមការណែនាំ និងចង្អុលបង្ហាញពីក្រុមត្រួតពិនិត្យ។ ក្រុមត្រួតពិនិត្យគួរគោរពតាមច្បាប់សុវត្ថិភាព និងបទដ្ឋានប្រតិបត្តិការពាក់ព័ន្ធរបស់ប្រតិបត្តិករសកម្មភាពមីន។

## ៥. ឆ្លើយតបទៅនឹងមិនអនុលោមភាព

ការរកឃើញភ័ស្តុតាងភាពមិនអនុលោមនៃផលិតផលជាបញ្ហាធ្ងន់ធ្ងរបំផុត។ ទីតាំង លក្ខណៈភ័ស្តុតាង និងតួនាទីអ្នកបោសសម្អាត គួរត្រូវបានចងក្រងជាឯកសារឱ្យបានត្រឹមត្រូវ។ ក្រុមត្រួតពិនិត្យគួរប្រើប្រាស់ផែនទី រូបថត និងឯកសារពាក់ព័ន្ធនានាដើម្បីសន្និដ្ឋានពីភាពមិនអនុលោម។

ឯកសារនៅការដ្ឋានអំពីការត្រួតពិនិត្យរបស់ក្រុម និងកំណត់ត្រារបស់ប្រតិបត្តិករគួររួមបញ្ចូលព័ត៌មានលម្អិតអំពីមិនអនុលោមភាព និងដំណោះស្រាយឆ្លើយតប។

ក្រុមត្រួតពិនិត្យអាចរកឃើញភ័ស្តុតាងផ្សេងៗទៀតនៃភាពមិនអនុលោមតិចតួច ទាក់ទងនឹងដំណើរការសកម្មភាពមីននៅពេលត្រួតពិនិត្យគុណភាព។ ភ័ស្តុតាងទាំងនោះគួរត្រូវបានដោះស្រាយដោយប្រើនីតិវិធីឆ្លើយតបដូចដែលបានកំណត់។

## ៦. សកម្មភាពកែតម្រូវ

ការវិភាគអំពីមូលហេតុឫសគល់នៃបញ្ហាគួរត្រូវបានធ្វើឡើងឱ្យបានហ្មត់ចត់ ក្នុងករណីរកឃើញភ័ស្តុតាងបង្ហាញពីភាពមិនអនុលោមនៃផលិតផល។ ផ្អែកលើកម្រិតនៃការតាមដាននៅក្នុងទិន្នន័យរបស់ប្រតិបត្តិករសកម្មភាពមីន អាចជួយបង្រួមមូលហេតុ និងរកឃើញម៉ាស៊ីន ឬឧបករណ៍ដែលប្រើ

ប្រាស់ហើយអាចកំណត់បាននូវទំហំសម្រាប់ការបោសសម្អាតឡើងវិញ។ កង្វះព័ត៌មានលម្អិតនាំឱ្យមានការពង្រីកទំហំ ឬអាចមានការបោសសម្អាតឡើងវិញទាំងស្រុង។

ក្រុមត្រួតពិនិត្យគួរយល់ស្របចំពោះសកម្មភាពកែតម្រូវ និងសកម្មភាពទប់ស្កាត់ការកើតឡើងវិញជាមួយប្រតិបត្តិករសកម្មភាពមីន។ សកម្មភាពកែតម្រូវ រួមមានការបោសសម្អាតផ្នែកខ្លះ ឬបោសសម្អាតទាំងស្រុងនៃទីតាំងដែលបានបោសសម្អាតរួច អាស្រ័យលើលទ្ធផលនៃការវិភាគពីមូលហេតុ។ បើចាំបាច់គ្រប់ការខ្វែងគំនិតគ្នារវាងក្រុមត្រួតពិនិត្យ និងប្រតិបត្តិករសកម្មភាពមីន គួរដាក់ជូនថ្នាក់ដឹកនាំជាន់ខ្ពស់។

## ៧. កំណត់ត្រាការត្រួតពិនិត្យ និងលទ្ធផល

រាល់សកម្មភាពត្រួតពិនិត្យរួមទាំងលទ្ធផលគួរត្រូវបានកត់ត្រាក្នុងឯកសារនៅការដ្ឋាន ឬតាមការណែនាំរបស់ក្រុមត្រួតពិនិត្យ។ ផែនទី រូបថត និងកំណត់ត្រាជាលាយលក្ខណ៍អក្សរនានា គួរត្រូវបានប្រើប្រាស់ដើម្បីផ្តល់នូវព័ត៌មានលម្អិតពេញលេញ និងច្បាស់លាស់អំពីសកម្មភាពត្រួតពិនិត្យដែលរកឃើញ និងសកម្មភាពតាមដានត្រូវអនុវត្តបន្ត។

## ៨. មធ្យោបាយផ្សេងៗក្នុងការរក្សាទំនុកចិត្តលើផ្ទៃដីដែលបានកាត់បន្ថយ

ការត្រួតពិនិត្យផ្ទៃដីត្រូវបានកំណត់ជាទំហំក្នុងទីតាំងដែលបានបោសសម្អាតរួច ជាឧបករណ៍សំខាន់ក្នុងការត្រួតពិនិត្យគុណភាព។ មានជម្រើសផ្សេងទៀតសម្រាប់ត្រួតពិនិត្យការអនុវត្តការកាត់បន្ថយផ្ទៃដី (C1 C2 និង C3)។ ការត្រួតពិនិត្យរយៈពេលយូរមានភាពសមស្របបំផុតដើម្បីស្វែងយល់អំពីអ្វីដែលបានកើតឡើងលើផ្ទៃដីបន្ទាប់ពីការកាត់បន្ថយ។

ភស្តុតាងនៃការសល់មីន/គ្រាប់ ឬគ្រោះថ្នាក់នៅលើផ្ទៃដីបានកាត់បន្ថយរួច គួរត្រូវបានស៊ើបអង្កេតដោយក្រុមត្រួតពិនិត្យអាជ្ញាធរមីន ដើម្បីស្វែងរកភាពមិនអនុលោមធ្ងន់ធ្ងរ។ គួរវិភាគពីមូលហេតុលើភស្តុតាងនាំឱ្យមានភាពមិនអនុលោមធ្ងន់ធ្ងរ និងកំណត់ការកែតម្រូវ និងសកម្មភាពទប់ស្កាត់សមស្រប។